**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ :** ២០៧ **កប** /ប្រក

## ប្រកាស

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការបម្រើការងារ

## នៅលេខាធិការដ្ឋាន នៃក.ប.ស.ស.

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨-១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ-បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីការបង្កើតក្រុមប្រឹក្សាបច្ចេកទេសរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- យោងប្រកាសលេខ ០៥៥ កប/ប្រក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅលេខាធិការដ្ឋាននៃក.ប.ស.ស.
- លិខិតលេខ ០៨១ មស/តត ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១១ របស់រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ
- លិខិតលេខ ០៨៦ មស/តត ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១១ របស់រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ១** ត្រូវបានតែងតាំងមន្ត្រីរាជការចំនួន ០៣ រូបឲ្យបម្រើការងារនៅលេខាធិការដ្ឋាន នៃ ក.ប.ស.ស. ដូចមានរាយនាមខាងក្រោម៖

១- លោកស្រី **លី សុភាខៀន** ជាប្រធានលេខាធិការដ្ឋានមានឋានៈស្មើប្រធានការិយាល័យថ្នាក់កណ្តាលបន្ថែមលើមុខងារបច្ចុប្បន្ន។

២- លោក **ឯម រតន៍មុន្នី** ជាអនុប្រធានលេខាធិការដ្ឋានមានឋានៈស្មើអនុប្រធានការិយាល័យថ្នាក់កណ្តាលបន្ថែមលើមុខងារបច្ចុប្បន្ន។

៣- លោកស្រី **សុខ ស៊ីនួន** ជាអនុប្រធានលេខាធិការដ្ឋាន មានឋានៈស្មើអនុប្រធានការិយាល័យថ្នាក់កណ្តាលបន្ថែមលើមុខងារបច្ចុប្បន្ន។

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩*

**ប្រការ២** នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកការងារ អគ្គនាយកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ អគ្គាធិការ ប្រធានទីភ្នាក់ងារមុខរបរ និងការងារ ប្រធានក្រុមប្រឹក្សាបច្ចេកទេសរបបសន្តិសុខសង្គម ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ នាយកបេឡាជាតិរបបសន្តិសុខសង្គម និងសាមីខ្លួនដូចមានឈ្មោះក្នុងប្រការ១ ខាងលើ ត្រូវមានភារកិច្ចអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១១

**រដ្ឋមន្ត្រី**

**វង្ស សុត**

**ចម្លងជូន:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រីប្រចាំការ
  " ដើម្បីជូនជ្រាប"
- ដូចប្រការ២ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ